ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តរតនគិរី**

*សំណុំរឿងព្រហ្មទណ្ឌ*

លេខ : ១៤៤

ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦

*សំណុំរឿងជំនុំជម្រះ*

លេខ : ៣៥

ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១

*សាលក្រមព្រហ្មទណ្ឌ*

លេខ : ៩១/១២ "ខ"

ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តរតនគិរី

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តរតនគិរី

កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១

កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១

ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

*ចៅក្រមជំនុំជម្រះ*

លោក [redacted] ឋានៈអនុប្រធានសាលាដំបូងខេត្តរតនគិរី

*តំណាងអយ្យការ*

លោក [redacted] ឋានៈព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តរតនគិរី

*ក្រឡាបញ្ជីសវនាការ*

កញ្ញា [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

*មេធាវី*

លោក [redacted] ឋានៈមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៤៤ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ដែលមាន ៖

ជនជាប់ចោទឈ្មោះ [redacted] ខុន ហៅ សង់ ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ នគរបាល ទីកន្លែងកំណើតនៅភូ[redacted] ខេត្តរតនគិរី មានទីលំនៅបច្ចុប្បន្ននៅសង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ប្រពន្ធឈ្មោះ[redacted]សុឃីម មានកូន៨នាក់ ឪពុកឈ្មោះ[redacted] សាំ (ស) ម្តាយឈ្មោះ[redacted]សុផាន (ស) ទោសពីមុនគ្មាន។ *(ក្រៅឃុំ)*

ជាប់ចោទពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅផ្ទះរបស់ឈ្មោះ[redacted] ការិមាន ស្ថិតនៅភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្នី ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្ននៅភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ។



Scanned with CamScanner

-**បានឃើញ** ដីកាដំណោះស្រាយ លេខ ៦៥២/២០ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តរតនគិរី។

## អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៦នាទីល្ងាច មានករណី **ហិង្សាដោយចេតនា** មួយកើតឡើងនៅចំណុចផ្ទះរបស់ឈ្មោះ [redacted] កានវិមាន ដែលបង្កឡើងដោយឈ្មោះ [redacted] ខុន បានវាយទៅលើជនរងគ្រោះឈ្មោះ [redacted] ចន្ធី។ ហេតុកាលនោះបានកើតឡើង នៅពេលដែលជនរងគ្រោះ បានទៅចូលរួមកម្មវិធីស៊ីផឹកនៅផ្ទះរបស់ឈ្មោះ [redacted] កានវិមាន ដែលមានគ្នាទាំងអស់ចំនួន៧នាក់ ពេលកំពុងផឹកឈ្មោះ [redacted] ខុន ហៅ សង់ បាននិយាយដើមអាក្រក់ពីឈ្មោះ [redacted] សាវួន ជាច្រើនដង ដោយជនរងគ្រោះលឺដូច្នេះក៏បានឃាត់ឈ្មោះ [redacted] ខុន កុំឱ្យទៅនិយាយអាក្រក់ពីឈ្មោះ [redacted] សាវួន ដែលជាមិត្តភក្តិរបស់ជនរងគ្រោះ ពេលនោះក៏មានការឈ្លោះប្រកែកគ្នាកើតឡើង ដោយឈ្មោះ [redacted] ខុន បានវាយទៅលើឈ្មោះ [redacted] ចន្ធី ចំនួនពីរដៃត្រូវចំត្រចៀកខាងឆ្វេងបណ្តាលឱ្យហើមមុខតែម្តង។ ក្រោយពេលកើតហេតុជនរងគ្រោះក៏បានមកដាក់ពាក្យបណ្តឹងនៅអយ្យការអមសាលាដំបូងខេត្តរតនគិរី ដើម្បីចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ខុន ឆ្លើយថា: កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៨យប់មានគ្នា៥នាក់ បានផឹកស្រាបៀរនៅផ្ទះរបស់ឈ្មោះ [redacted] កានវិមាន ផឹកស្រាបៀបានមួយសន្ទុះឈ្មោះ [redacted] ចន្ធី បាននិយាយរំលឹករឿងចាស់ៗ ដដែលៗ ខ្ញុំក៏បានប្រាប់ឈ្មោះ [redacted] ចន្ធី កុំនិយាយ។ ខ្ញុំក៏បានទះផ្គាល់ឈ្មោះ [redacted] ចន្ធី ចំនួន២ដៃត្រូវថ្ពាល់ខាងឆ្វេង និងខាងស្តាំ ពេលទះនោះគឺខ្ញុំមិនមានបំណងវាយគាត់ទេ គឺលេងៗនោះទេ។ ដោយមានឈ្មោះ យូ កានវិមាន , ឈ្មោះ [redacted] ចាន់ថុល ,ឈ្មោះអ្នកកាសែតពីរនាក់ទៀត ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះទេ ធ្វើជាសាក្សីដឹងឮ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ធី ឆ្លើយថា: កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៦ល្ងាច ខ្ញុំបានទៅចូលរួមកម្មវិធីផឹកស៊ីនៅផ្ទះឈ្មោះ [redacted] កានវិមាន ដោយមានអ្នកចូលរួមចំនួន០៧នាក់ ខ្ញុំស្គាល់តែឈ្មោះ [redacted]ណា និងឈ្មោះ [redacted] កានវិមាន ដែលជាម្ចាស់ផ្ទះ។ ចំណែកអ្នកផ្សេងខ្ញុំមិនស្គាល់ទេ។ ពេលកំពុងផឹកស៊ីឈ្មោះ [redacted] ខុន បាននិយាយដើមអាក្រក់ពីឈ្មោះ [redacted] សាវួន ហើយខ្ញុំក៏ឃាត់កុំឱ្យនិយាយដើមគាត់សុទ្ធតែជាពួកម៉ាកយើងនោះទេ។ ពួកខ្ញុំបានប្រកែកគ្នា ខ្ញុំក៏បាននិយាយថា ហែងមកក្រោយគេទេចេះដឹងអី ភ្លាមនោះឈ្មោះ [redacted] ខុន បានវាយខ្ញុំចំនួន២ដៃ ត្រូវពីក្រោយជិតស្លឹកត្រចៀក ប៉ុន្តែមិនបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរនោះទេ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានពិនិត្យសំណុំរឿង និងឯកសារផ្សេងៗ តំណាងអយ្យការយល់ឃើញថា ពិតជាមានអង្គហេតុ ហិង្សាដោយចេតនា ប្រព្រឹត្តដោយឈ្មោះ [redacted] ខុន ហៅ សង់ ទៅលើជនរងគ្រោះឈ្មោះ [redacted] ចន្ធី ប្រាកដមែន។ ដូច្នេះតំណាងអយ្យការរក្សាបទចោទប្រកាន់នៅដដែរ ស្នើសុំតុលាការសម្រេចតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារ: ក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំតុលាការពិចារណាលើព្យសនកម្មដែលកើតឡើង មិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរនោះទេ។ ម្យ៉ាងទៀត



Scanned with CamScanner

ដោយសារតែកូនក្តីខ្ញុំ និងដើមបណ្តឹងរដ្ឋប្បវេណីបានផឹកស៊ីស្រវឹងជាមួយទើបធ្វើឱ្យមានទាស់ពាក្យសម្តីគ្នា។ មួយវិញទៀតនោះ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានដកពាក្យបណ្តឹងហើយដែរ ដូច្នេះស្នើសុំតុលាការផ្តល់នូវគោលការណ៍ព្យួរទោសដល់កូនក្តីខ្ញុំបាទ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារ និងកំណត់ហេតុផ្សេងៗ ។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងខេត្តរតនគិរី
## យល់ឃើញថា

១/ ដីកាដំណោះស្រាយលេខ ៦៥២/២០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តរតនគិរី សម្រេចបញ្ជូនសំណុំរឿងមកជំនុំជម្រះ ដែលមានជនជាប់ចោទឈ្មោះ [redacted] ខុន ហៅ **សង់** ភេទប្រុស អាយុ ៥៣ឆ្នាំ ពីបទ **ហិង្សាដោយចេតនា** ។

២/ តាមពាក្យបណ្តឹង និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ទី បានឱ្យដឹងថា ខ្លួន និងឈ្មោះ [redacted] ខុន បានឈ្លោះប្រកែកគ្នា ហើយឈ្មោះ [redacted] ខុន បានវាយខ្លួនចំនួន២ដៃ បណ្តាលឱ្យហើម។

៣/ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ខុន បានសារភាពថា ខ្លួនពិតជាបានទះថ្ពាល់ឈ្មោះ [redacted] ចន្ទី ចំនួន២ដៃ ត្រូវខាងឆ្វេង និងខាងស្តាំ។ ចម្លើយនេះស៊ីសង្វាក់គ្នានឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាចម្លើយដាក់បន្ទុកលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

៤/ ផ្អែកតាមពាក្យបណ្តឹង, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ,ចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា អំពើរបស់ជនជាប់ចោទ ត្រូវនឹងធាតុផ្សំបទល្មើស ហិង្សាដោយចេតនា ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៥/ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ខុន ហៅ **សង់** ពីបទ **ហិង្សាដោយចេតនា** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណា។

៦/ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំព្យួរទោសកូនក្តីរបស់ខ្លួន តុលាការយល់ឃើញថា ព្យសនកម្មដែលបង្កឡើងដោយជនជាប់ចោទមិនមានភាពធ្ងន់ធ្ងរនោះទេ ដូច្នេះគប្បីពិចារណា។

៧/ ជនជាប់ចោទឈ្មោះ **ម៉ោញ** ហៅ ខុន ភេទប្រុស អាយុ៥៣ឆ្នាំ មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៨/ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើ ជនជាប់ចោទឈ្មោះ [redacted] ខុន ហៅ ខុន ភេទប្រុស អាយុ៥៣ឆ្នាំ ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅផ្ទះរបស់ឈ្មោះ [redacted] ការិមាន ស្ថិតនៅភូមិទេសអន្លង់ សង្កាត់បឹងន្សែង ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៩/ អំពើដែលជនជាប់ចោទឈ្មោះ [redacted] ខុន ហៅ សង់ បានប្រព្រឹត្ត គឺធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសបង្កឱ្យមានរបួសស្នាមដល់អ្នកដទៃ។ ប៉ុន្តែជនរងគ្រោះពុំមានរបួសស្នាមធ្ងន់ធ្ងរនោះទេ ដូច្នេះទណ្ឌកម្មដែលត្រូវអនុវត្តលើជនជាប់ចោទតុលាការនឹងពិនិត្យពិចារណា។

១០/ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ទី បានសម្របសម្រួលគ្នារួចហើយ និងបានដកពាក្យបណ្តឹងផងដែរ ដូច្នេះដើមបណ្តឹងមិនទាមទារសំណងជំងឺចិត្តពីជនជាប់ចោទទេ ហេតុនេះតុលាការមិនពិចារណាសម្រេចឡើយ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **ខុន** ហៅ **សង់** ភេទប្រុស អាយុ៥៣ឆ្នាំ (សាវតារជាតិដូចខាងលើ) កំណត់រយៈពេល *១ (មួយ) ឆ្នាំ តែអនុវត្តទោសព្យួរធម្មតា* ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅផ្ទះរបស់ឈ្មោះ [redacted] ការិមាន ស្ថិតនៅភូមិទេសអន្លង់ សង្កាត់បឹងន្សែង ក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០៦ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចាត់ទុកចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ អង្គារ ៤រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រតនគិរី, ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner